# KHMER- WHOOPING COUGH VACCINATION IN PREGNANCY

# ការចាក់ថ្នាំបង្ការរោគក្អកមាន់នៅពេលមានផ្ទៃពោះ

### ❖ តើរោគក្អកមាន់ជាអ្វី?

- ក្អកមាន់គឺជារោគមួយដ៏ធ្ងន់ធ្ងរណាស់ដោយការចម្លងពីមេរោគប៉ាក់តេរី។
- ក្អកមាន់អាចបង្កឲ្យការក្អកប្រកួតក្នុងពេលដ៏យូរ ដោយធ្វើឲ្យទារកមានការពិបាកខ្លាំងក្នុងការដកដង្ហើម។
- ទារកខ្លះអាចមានផលពិបាកដ៏ធ្ងន់ធ្ងរក្នុងការលូតលាស់ដូចជាមាន៖ ជម្ងឺរលាកសួត នឹងការខូចដល់ខួរក្បាលផង។
- ទារកភាគច្រើនបានតម្រូវចូលទៅព្យាបាលក្នុងមន្ទីរពេទ្យពេលដែលរោគនេះកាន់តែធ្ងន់ធ្ងរទារកអាចនឹងស្លាប់។

### ❖ តើអ្វីជាការចាក់ថ្នាំបង្ការរោគនេះ?

- ការចាក់ថ្នាំបង្ការរោគផ្សេងៗ គឺការពារដល់កុមារនឹងមនុស្សពេញវ័យទាំងឡាយពីការបង្កនូវគ្រោះថ្នាក់ដោយការចម្លងមេរោគផ្សេងៗ។
- ការចាក់ថ្នាំបង្ការរោគបានបង្កើនឡើងនូវភាពការពារដល់ប្រព័ន្ធនៅក្នុងសរីរាង្គកាយដើម្បីប្រយុទ្ធប្រឆាំងនឹងមេរោគចម្លងដ៏សាហាវមួយចំនួនដូចជា៖ រោគរលាកថ្លើមបេ រោគក្អកមាន់ រោគកញ្ជ្រិល រោគស្រឡទែននឹងរោគស្អូច។
- ថ្នាំវ៉ាក់សាំងបង្ការរោគមានមួយចំនួនជាផ្នែកនៃមេរោគវីរុស ឬមេរោគប៉ាក់តេរី ដោយផ្សំបន្ថែមនូវផ្នែកខ្លះទៀតដូចជាការរក្សាបណ្ដុះផ្អាប់ទុកយូរឬមានសមាសធាតុខ្លះដើម្បីបង្កើននូវប្រព័ន្ធស៊ាំនឹងរោគឲ្យបានកាន់តែប្រសើឡើង។

### ❖ ហេតុអ្វីស្ត្រីមានផ្ទៃពោះគួរតែចាក់ថ្នាំវ៉ាក់សាំងសំរាប់បង្ការរោគក្អកមាន់នេះ?

- ការបានទទួលថ្នាំវ៉ាក់សាំងបង្ការរោគក្អកមាន់ក្នុងខណះស្ត្រីមានផ្ទៃពោះនឹងអាចជួយការពារដល់ទារកអ្នកពីការកើតមានរោគក្អកមាន់ ពេលប៉ុន្មានអាទិត្យដំបូងនៃជីវិតរបស់ទារក។
- សមាភាពស៊ាំរោគា ដែលអ្នកបានទទួលពីថ្នាំវ៉ាក់សាំងនេះ នឹងបញ្ជូនទៅកាន់ទារករបស់អ្នកដោយឆ្លងកាត់តាមសុក។
- ទារកទាំងឡាយចាប់ផ្ដើមការចាក់ថ្នាំបង្ការរោគក្អកមាន់នេះ នៅពេលមានអាយុ **6** អាទិត្យ ប៉ុន្តែមិនប្រាកដជាអាចការពារពេញលេញបានទេ រហូតទាល់តែបន្ទាប់ពីទារក បានចាក់ថ្នាំចំនួន **2** ដូសទៀត ជាធម្មតាគឺពេលទារកបានអាយុ **4** ខែ។

### ❖ តើថ្នាំវ៉ាក់សាំងចាក់បង្ការរោគក្អកមាន់នេះ ប្រកបដោយសុវត្ថិភាពចំពោះស្ត្រីមានផ្ទៃពោះដែរ?

- គឺពិតជាប្រកបដោយសុវត្ថិភាព។ គឺគ្មានភ័ស្តុតាងដោយបញ្ជាក់ពីថ្នាំវ៉ាក់សាំងដែលមិនប្រកបដោយសុវត្ថិភាពមានដល់ម្តាយនឹងទារកនោះឡើយ។
- គឺគ្មានភ័ស្តុតាំងដោយបញ្ជាក់ពីថ្នាំវ៉ាក់សាំងអាចបណ្ដាលឲ្យមានជម្ងឺណាមួយដល់ម្តាយក៏ដូចជាដល់ទារកឡើយ។

### ❖ បើសិនជាខ្ញុំបានចាក់ថ្នាំវ៉ាក់សាំងបង្ការរោគក្នុងរយះពេលពី 2 ឆ្នាំកន្លងមក តើខ្ញុំត្រូវការចាក់បង្ការរោគនេះទៀតដែរ?

- គឺពិតណាស់ ដោយស្នើដល់ស្ត្រីមានផ្ទៃពោះទាំងឡាយត្រូវទទួលការថ្នាំវ៉ាក់សាំងបង្ការរោគនេះរាល់ពេលមានផ្ទៃពោះ ដោយមិនគិតតាំងពីពេលដែលគេបានចាក់ថ្នាំបង្ការនេះនៅពេលចុងក្រោយកន្លងមកក៏ដោយ។

### ❖ តើអ្នកអាចបានទទួលការចាក់ថ្នាំវ៉ាក់សាំងបង្ការរោគក្អកមាន់ដោយរបៀបណាដែរ?

- ការចាក់ថ្នាំវ៉ាក់សាំងនេះ បានសូមស្នើឲ្យចាក់បង្ការនៅពេលត្រីមាសទី **3** ដោយគំនិតចងចាំនៅរវាងពេល **28** ទៅ **32** អាទិត្យ។
- ថ្នាំវ៉ាក់សាំងនេះគឺមានផ្តល់ជូននៅ៖
  - **MMC Clayton** (មន្ទីរពេទ្យម៉ូណាស់ខ្លិចតិន)

    កន្លែងចាក់ថ្នាំបង្ការរោគ **Monash Immunisation:** ផ្នែកអគារឯកជន នៅជាន់ទី **2 (Private suite I Jessie MacPherson) Level 2** ។

    ទូរស័ព្ទលេខ: 9594 6320 ចាប់ធ្វើការពីម៉ោង **8.30**ព្រឹក ដល់ម៉ោង **4** រសៀល ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។ **(Monday to Friday from 8.30am – 4.00pm )**

    **មិនចាំបាច់ធ្វើការណាត់ជួបឡើយៗ**
- ប្រសិនជាអ្នកបានកក់កំណត់សំរាលនៅមន្ទីរពេទ្យ Dandenong ឬនៅ Casey មានផ្តល់ជូនផងដែរនៅ៖
  - **Dandenong**

    មន្ទីរគ្លីនិកសំរាប់ការថែទាំដល់ស្ត្រីដែលមានផ្ទៃពោះ
  - **Casey**

    មន្ទីរគ្លីនិក Pakenham សំរាប់ការថែទាំផ្ទៃពោះ។

*OCTOBER 2016*

MonashHealth